THE SCHOOL DISTRICT OF PHILADELPHIA

**Office of Federal Programs**
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០២៤

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

ក្នុងនាមជាមាតាបិតា ឬអាណាព្យាបាលរបស់សិស្សដែលរៀននៅសាលាដែលទទួលប្រាក់សហព័ន្ធ Title I ។ លោកអ្នកមានសិទ្ធិដឹងពីលក្ខណៈសម្បត្តិវិជ្ជាជីវៈរបស់គ្រូ និងការបង្ហាត់បង្រៀនដោយអ្នកជំនួយរបស់គ្រូ (paraprofessional) ដែលបង្រៀនកូនលោកអ្នក។

ច្បាប់រដ្ឋសហព័ន្ធតម្រូវឱ្យក្រសួងអប់រំដែលទទួលប្រាក់ Title I ទាំងអស់ អនុវត្តតាម និងផ្តល់ឱ្យលោកអ្នកនូវ
ព័ត៌មានដែលបានស្នើសុំឱ្យទាន់ពេលវេលា។ សាលាទាំងអស់មានបញ្ជីឈ្មោះសមាជិកបុគ្គលិក និងលក្ខណៈសម្បត្តិវិជ្ជាជីវៈរបស់ពួកគេ។ លោកអ្នកអាចសាកសួរនៅពេលណាក៏បាន៖

- ថាតើគ្រូបង្រៀនមានលក្ខណៈសម្បត្តិ និងវិញ្ញាបនប័ត្រ តាមតម្រូវការរបស់រដ្ឋ សម្រាប់កម្រិតថ្នាក់ និងមុខវិជ្ជាដែលគាត់បង្រៀន ឬអត់
- ថាតើគ្រូបានទទួលវិញ្ញាបនប័ត្រសម្រាប់ពេលបន្ទាន់ ឬតាមលក្ខខណ្ឌដែលលក្ខណៈសម្បត្តិរបស់រដ្ឋត្រូវបានលើកលែងឬអត់ ហើយ
- តើសញ្ញាប័ត្របរិញ្ញាប័ត្រ ឬសញ្ញាប័ត្រអនុបណ្ឌិតផ្នែកអ្វីដែលគ្រូទទួល រួមទាំងសញ្ញាប័ត្រអនុបណ្ឌិត និងសញ្ញាប័ត្របន្ថែម និងមុខវិជ្ជាសិក្សា ឬវគ្គដែលផ្តោតលើមុខវិជ្ជាសិក្សាមួយចំនួន។

លោកអ្នកក៏អាចសាកសួរ ថាតើកូនលោកអ្នកទទួលជំនួយពីអ្នកជួយគ្រូដែរឬទេ។ ប្រសិនបើកូនលោកអ្នក
ទទួលជំនួយនេះ យើងអាចផ្តល់ព័ត៌មានអំពីលក្ខណៈសម្បត្តិរបស់អ្នកជួយគ្រូ។

ច្បាប់ស្តីពីភាពជោគជ័យរបស់សិស្សគ្រប់រូប [Every Student Succeeds Act (ESSA)] ដែលត្រូវបានចុះហត្ថលេខាឱ្យក្លាយជាច្បាប់ក្នុងខែធ្នូ ឆ្នាំ ២០១៥ រួមបញ្ចូលទាំងសំណើនៃសិទ្ធិដែលត្រូវដឹង។ លោកអ្នកអាចស្នើសុំនៅពេលណាក៏បាន៖

- ព័ត៌មានស្តីពីច្បាប់ទាក់ទងនឹងការចូលរួមរបស់សិស្សក្នុងការវាយតម្លៃ និងវិធីសម្រាប់ការជ្រើសរើសមិនចូលរួមក្នុងការវាយតម្លៃ និង
- ព័ត៌មានស្តីពីការវាយតម្លៃចាំបាច់ ដែលរួមមាន៖
    - ប្រធានបទនៃការធ្វើតេស្ត/ subject matter tested
    - គោលបំណងនៃការធ្វើតេស្ត/ purpose of the test
    - ប្រភពនៃតម្រូវការ (ប្រសិនបើមាន) / source of the requirement (if applicable)
    - រយៈពេលដែលសិស្សបញ្ចប់ការធ្វើតេស្ត និង/ amount of time it takes students to complete the test, and
    - ពេលវេលា និងទម្រង់នៃការចែកលទ្ធផល/ time and format of disseminating results។

បុគ្គលិករបស់យើងប្តេជ្ញាជួយកូនលោកអ្នកអភិវឌ្ឍនូវជំនាញដែលគេត្រូវការដើម្បីឱ្យមានជោគជ័យនៅសាលា និងលើសពីនេះ។ ការប្តេជ្ញាចិត្តនោះរួមបញ្ចូលទាំងការធ្វើឱ្យប្រាកដថា គ្រូ និងអ្នកជំនួយរបស់គ្រូទាំងអស់របស់យើង បំពេញតាមតម្រូវការរបស់រដ្ឋ ផិនស៊ីលវេនញ៉ា នូវអ្វីៗដែលពាក់ព័ន្ធ។ យើងទន្ទឹងរង់ចាំឆ្នាំសិក្សានាពេលខាងមុខនេះ ហើយតាមការរួមគ្នា យើងនឹងធ្វើឱ្យជីវិតរបស់កូនលោកអ្នកមានការផ្លាស់ប្តូរ។

ដោយសេចក្តីស្មោះស្ម័គ្គ

agcrockett

Ashley Glasgow-Crockett
នាយិកានៃកម្មវិធីសហព័ន្ធ និងការអនុលោមតាមច្បាប់